ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

# ជំនួបរវាងឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
## និង លោកស្រី Lene Kroll Christiansen តំណាងអង្គការ UNFPA

នៅព្រឹកថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង១០:០០ នៅទីស្តីការក្រសួង **ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យលោកស្រី Lene Kroll Christiansen តំណាងថ្មីរបស់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

ជាបឋមលោកស្រី Lene Kroll Christiansen បានប្រគល់ជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** នូវលិខិតរបស់អង្គការ UNFPA តែងតាំងលោកស្រី ជាតំណាងថ្មីនៅកម្ពុជា ។

ក្នុងឱកាសនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងការអបអរសាទរ និងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះការចូលកាន់តំណែងរបស់លោកស្រី Lene Kroll Christiansen នៅកម្ពុជា។ **ឯកឧត្តម** បានវាយតម្លៃខ្ពស់ចំពោះបទពិសោធន៍របស់លោកស្រីឆ្លងតាមការបំពេញការងារនៅទីស្នាក់ការកណ្តាលរបស់ UNFPA នៅទីក្រុងញូវយ៉ក ហើយនិងជាតំណាងរបស់ UNFPA នៅប្រទេស Yemen, Sri Lanka, Maldives និងបានគូសបញ្ជាក់ថា ជាមួយបទពិសោធន៍ទាំងនេះលោកស្រីនឹងសម្រេចបានដោយជោគជ័យ ក្នុងការបំពេញការងារជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានរំលឹកឡើងវិញអំពីការរួមវិភាគទានដ៏សកម្មរបស់តំណាង UNFPA មុននេះ ក្នុងការអនុវត្តនូវបណ្តាគម្រោងនានា ក្រោមការជួយឧបត្ថម្ភរបស់អង្គការនេះ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាចំពោះការជួយឧបត្ថម្ភគ្រប់បែបយ៉ាងរបស់អង្គការUNFPA ចាប់តាំងពីការបង្កើតការិយាល័យរបស់អង្គការនេះ នៅកម្ពុជា ក្នុងឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ននេះ និងបានវាយតម្លៃខ្ពស់ចំពោះការរួមចំណែករបស់អង្គការ UNFPA ក្នុងការអនុវត្តនូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស (MDGs) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព (SDGs) នាពេលបច្ចុប្បន្ននេះ។

លោកស្រី Lene Kroll Christiansen បានសំដែងនូវក្តីរីករាយចំពោះការតែងតាំងលោកស្រីអោយមកបំពេញការងារនៅព្រះរាជាណាចក្រកម្ពុជា ហើយលោកស្រីក៏បានគូសបញ្ជាក់អំពីការចាប់អារម្មណ៍របស់លោកស្រី ចំពោះការរីកចំរើនលើគ្រប់វិស័យនៅកម្ពុជា ពិសេសអំពីជីវភាពរស់នៅពោរពេញដោយសន្តិភាព សុវត្ថិភាព និងសន្តិសុខដ៏ល្អប្រសើរនៅប្រទេសកម្ពុជា។

លោកស្រី បានជំរាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី**ថា នៅក្នុងការបំពេញការងាររបស់លោកស្រីនៅកម្ពុជា លោកស្រីនឹងផ្តោតជាសំខាន់ទៅលើការជួយដល់ស្ត្រី និងការអនុវត្តនូវគំពេងផ្សេងៗ

ដែលជាគុណប្រយោជន៍ដល់ប្រជាជនកម្ពុជា។ លោកស្រីបានសំដែងនូវការពេញចិត្តចំពោះលទ្ធផលដែលទទួលបានក្នុងកិច្ចសហប្រតិបត្តិការរវាងអង្គការUNFPA ជាមួយបណ្ដាក្រសួង និងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តនូវគម្រោងជំនួយឧបត្ថម្ភរបស់អង្គការ UNFPA នៅកម្ពុជា ពិសេសការរីកចំរើននៅក្នុងការកាត់បន្ថយអត្រាមរណៈក្នុងពេលសំរាលបុត្រ។

លោកស្រី Lene Kroll Christiansen ក៏បានជំរាបជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីគម្រោងជួយឧបត្ថម្ភរបស់អង្គការ UNFPA ចំពោះកម្ពុជា នាពេលកន្លងមក ក៏ដូចជាគម្រោងនាពេលបច្ចុប្បន្នសំរាប់ឆ្នាំ ២០១៦ ដល់ ២០១៨ ហើយបានសំដែងនូវការអបអរសាទរចំពោះកម្ពុជា ដែលត្រូវបានចាត់បញ្ចូលទៅក្នុងក្រុមប្រទេសដែលមានចំណូលមធ្យមកំរិតទាប។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជំរាបជូនតំណាងUNFPA ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះបញ្ហាដែលពាក់ព័ន្ធនឹងសុខុមាលភាពរបស់ប្រជាជន ពិសេសគឺកិច្ចការនារី តាមរយៈការលើកកំពស់សមភាពយេនឌ័រ ការផ្ដល់អំណាចដល់ស្ត្រី និងការប្រឆាំងនឹងអំពើហិង្សាលើស្ត្រីភេទ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរបស់មូលនិធិប្រជាជនអង្គការសហប្រជាជាតិ ក្នុងការជួយអប់រំស្ដីពីសុខភាពផ្លូវភេទនិងការមានបុត្រតាមបំណងប្រាថ្នាពិសេសក្នុងស្រទាប់យុវវ័យ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកអំពីបញ្ហាដែលកំពុងតែចោទមានឡើងនៅកម្ពុជាពាក់ព័ន្ធនឹងការពរពោះជំនួស ហើយបានគូសបញ្ជាក់អំពីការខិតខំរបស់បណ្ដាស្ថាប័នពាក់ព័ន្ធកម្ពុជាដើម្បីទប់ស្កាត់មិនឲ្យបុត្រដែលកើតមកតាមរយៈការពរពោះជំនួសនេះ ក្លាយជាជនរងគ្រោះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់អំពីការខិតខំរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយអត្រាមរណៈក្នុងពេលសំរាលបុត្រ ពិសេសគឺតាមរយៈការលើកទឹកចិត្តមាតាអោយទៅសំរាលបុត្រនៅតាមមន្ទីរសម្ភពនៃមណ្ឌលសុខភាពនានា ដែលមានសុវត្ថិភាពច្រើនជាងនៅផ្ទះ ហើយនិងការកែលំអគុណភាពសេវា និងការផ្ដល់សេវា ដោយឥតគិតថ្លៃ នៅតាមមណ្ឌលសុខភាពទាំងអស់នោះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានលើកឡើងអំពីភាពងាយស្រួលក្នុងការអនុវត្តផែនការគ្រួសារនៅកម្ពុជា ដោយបច្ចុប្បន្ននេះ ប្រជាជនកម្ពុជាមានការយល់ដឹង និងបានគ្រប់គ្រងដោយខ្លួនឯងនូវការមានបុត្រ តាមបំណងប្រាថ្នារបស់ខ្លួន។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជំរាបជូន លោកស្រី Lene Kroll Christiansen អំពីការត្រៀមលក្ខណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការជួយសំរួលដល់ការបំពេញភារកិច្ចការងាររបស់លោកស្រី នៅកម្ពុជា ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៧